៥៤២/០៦.០៥.១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**ព្រៃវែង**

សំណុំរឿង រដ្ឋប្បវេណី
លេខ១៨៤ ចុះថ្ងៃទី១១
ខែ កញ្ញា ឆ្នាំ ២០០៩

**សាលក្រម**
លេខ ១៩ "ឃ"
ចុះថ្ងៃទី ២៧ ខែ ធ្នូ
ឆ្នាំ ២០១០

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រៃវែង**

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

ថ្ងៃប្រកាសសាលក្រមថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] **ចៅក្រមសាលាដំបូងខេត្តព្រៃវែង**

**ក្រឡាបញ្ជី**

លោក [redacted] **ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង** ។

ដើមចោទ : គណៈកម្មការវត្តព្រះជីវីធំ គណៈកម្មការទ្រទ្រង់សាលារៀនព្រះជីវីធំ មានឈ្មោះ [redacted] **សុខុម** , ឈ្មោះ [redacted] **សុខ** , ឈ្មោះ [redacted] **ឡាច** , ឈ្មោះ [redacted] **យួម** និងឈ្មោះ [redacted] **សាវិន** ដែលមានមេធាវីតំណាងដោយអាណត្តិគឺលោក [redacted] **វុន** និងលោក [redacted] **គឹមលន់** ។

ចុងចំលើយឈ្មោះ [redacted] **សាំង** ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្នភូមិកណ្តាល ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ដែលមានមេធាវីតំណាងដោយអាណត្តិគឺលោក [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

**១- ការទាមទារ :**

ដើមចោទទាមទារដីទំហំ ១២៥៣ $ម^2$ ពីចុងចំលើយឈ្មោះ [redacted] **សាំង** ។

**២- ដំណើររឿងក្តី :**

ភាគីដើមចោទថាចុងចំលើយឈ្មោះ [redacted] **សាំង** បានសុំដីដែលកំពុងមានទំនាស់ពីព្រះចៅអធិការវត្តព្រះនាម [redacted] **ចាវ** (បច្ចុប្បន្នសុគតហើយ) ដើម្បីធ្វើស្រែចិញ្ចឹមជីវិត ហើយឈ្មោះ [redacted] សាំង នេះបានរំលោភយកដីខាងលើនេះបំណងយកធ្វើជាកម្មសិទ្ធិ ។

**៣- ចំណុចវិវាទ :**

តើចុងចំលើយឈ្មោះ [redacted] សាំង បានរំលោភយកដីរបស់ភាគីដើមចោទដែល



Scanned with CamScanner

19/7

មានទំហំ ១២៥៣ ម៉ែត្រការ៉េ មែនដែរ ឬទេ ? ។

## ៤- ការអះអាងរបស់ភាគី

### ក-ការអះអាងរបស់ដើមចោទ

- មេធាវីរបស់ដើមចោទថា ដំបូងឡើយដីសាលារៀនព្រះជីវីធំ គឺដីដែលបំបែកចេញពីដីវត្តព្រះជីវីធំដែលមមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ ។ ដីដែលកំពុងមានទំនាស់ទំហំ ១២៥៣ ម៉ែត្រការ៉េ ឈ្មោះ [redacted] សាំង បានមកសុំដីទំនាស់នេះពីព្រះចៅអធិការព្រះនាម [redacted] ថាវ ដើម្បីធ្វើស្រែចិញ្ចឹមជីវិត ។ ក្រោយមកលោក [redacted] សាំង ក៏បានស្នើសុំទៅអាជ្ញាធរមូលដ្ឋានសុំធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើដីដែលបានខ្ចីពីសាលាដើម្បីធ្វើស្រែនេះ តែអាជ្ញាធរមិនបានអនុញ្ញាតទេ ស្រាប់តែមកដល់អំឡុងឆ្នាំ ២០០៨ ក៏បានឃើញការបោះបង្គោលថ្មនៅលើដីនោះ និងមានការកាប់ដីលុបលើដីនោះថែមទៀតផង ទើបភាគីខាងសាលារៀន និងវត្តមានការប្តឹងមកតុលាការនេះ ។

- ដើមចោទឈ្មោះ [redacted] សុខុម ថា ដីរបស់សាលាដែលបានកាន់កាប់តាំងពីឆ្នាំ ១៩៧៩ មក គឺមានព្រំប្រទល់ប៉ែកខាងលិច ទល់និងផ្លូវជាតិលេខ ១ ។ ខ្ញុំបានធ្វើជានាយកសាលាព្រះជីវីធំតាំងពីឆ្នាំ ១៩៩៨ ។ ចំពោះប្លង់សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ ខ្ញុំទទួលស្គាល់ ពីព្រោះពេលចុះវាស់វែងមានភូមិបាល តំណាងគណៈកម្មាការអាចារ្យ តំណាងសហគមន៍ ។ ដីទំនាស់នេះឈ្មោះ [redacted] សាំង ធ្វើស្រែរហូតមក ពេលគេចុះវាស់វែងឈ្មោះ [redacted] សាំង ពុំមានធ្វើការតវ៉ាអ្វីទេ ។ ក្នុងរឿងនេះ ខ្ញុំសុំទាមទារយកដីសាលាតាមប្លង់ដែលមានព្រំប្រទល់ប៉ែកខាងលិចទល់ផ្លូវជាតិលេខ ១ ។

- ដើមចោទឈ្មោះ [redacted] សាវិន ថា ដីសាលារៀនព្រះជីវីធំ បានធ្វើការអង្កេតវាស់វែងនៅឆ្នាំ ១៩៩៥ ហើយនៅពេលនោះពុំទាន់មានអ្នកណាជំទាស់ទេ ។ ចំពោះឈ្មោះ [redacted] សាំង ខ្ញុំឃើញគាត់កាន់កាប់បង្កបង្កើនផលនៅឆ្នាំ ១៩៨៦ ។ ខ្ញុំពុំបានឃើញឈ្មោះ [redacted] សាំង ខ្ចីដីនេះពីលោកតា [redacted] ថាវ ដោយផ្ទាល់ទេ តែខ្ញុំបានដឹងថា ឈ្មោះ [redacted] សាំង បានសុំពីលោកតាថាវ ពិតមែនពីឆ្នាំ ១៩៧៩ ។ ចំពោះដីទំនាស់ជាមួយសាលារៀន នេះគាត់បានកាន់កាប់រុករានតាំងពីឆ្នាំ ១៩៧៩ រហូតមក ។ ខ្ញុំបានដឹងតាមកំណត់ហេតុចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨

- ដើមចោទឈ្មោះ [redacted] ឃួម ថា ខ្ញុំចូលមកបង្រៀននៅឆ្នាំ ១៩៩៥ ដីទំនាស់ នេះវាស់វែងព្រំប្រទល់ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ



Scanned with CamScanner

19/6

ខាងជើងទល់ ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ឬង់ធ្លាក់មកដល់សាលារៀននៅឆ្នាំ ១៩៩៧ ពេលនោះខ្លួនពុំបានដឹងថាបាត់ដីទេ បើពេលនោះដឹងថាបាត់ដីម្ល៉េះតវ៉ានៅពេលនោះហើយ ទើបតែពេលក្រោយឃើញឈ្មោះ [redacted] សាំង បោះបង្គោល ទើបដឹងថាបាត់ដីសាលារៀន ។/

- ដើមចោទឈ្មោះ [redacted] **សន** ថា ដីសាលារៀនមានព្រំប្រទល់ ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ។/

- ដើមចោទឈ្មោះ [redacted] **ឡាច** ថា ដីសាលារៀនមានព្រំប្រទល់ ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ។/

**ខ- ការអះអាងរបស់ចុងចំលើយ :**

មេធាវីតំណាងដោយអាណត្តិរបស់ចុងចំលើយថា ដីទំនាស់នេះកូនក្តីរបស់ខ្លួនកាន់កាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ដោយពុំមានការជំទាស់ពីអ្នកណាឡើយ ស្រាប់តែមកដល់ឆ្នាំ ២០០៨ នាយកសាលាព្រះជីវីធំបានដាក់ពាក្យបណ្តឹងមកអយ្យការខេត្តព្រៃវែង ថាកូនក្តីរបស់ខ្លួនឈ្មោះ [redacted] សាំង បានបោះបង្គោលរំលោភយកដីសាលាព្រះជីវីធំ ដែលតាមពិតដីនេះ គឺជាដីរបស់កូនក្តីខ្លួនឈ្មោះ [redacted] សាំង ពិតប្រាកដ ។ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៨ អយ្យការខេត្តព្រៃវែង បានតម្កល់រឿងទុកឥតចាត់ការលើពាក្យបណ្តឹងរបស់នាយកសាលាព្រះជីវីធំ នោះខ្លួនសុំប្រានបោលនូវការទាមទាររបស់ដើមចោទ។

- ចុងចំលើយឈ្មោះ [redacted] **សាំង** ថា ដីទំនាស់នេះខ្លួនបានកាន់កាប់ និងបង្កបង្កើនផលតាំងពីឆ្នាំ ១៩៧៩ មក ។ កាលពីដើមឡើយដីនេះជាដីព្រៃសិប្ញូវទៅដោយដើមកប្បាស់ព្រៃ និងដើមថ្នឹមអណ្តើកស្មៅក្រាស់ៗ និងមានសំណល់គ្រាប់ផ្ទុះជាច្រើនដែលខ្លួនបានកាប់ឆ្ការលើដីនេះ និងប្រមែប្រមូលសំណល់គ្រាប់ផ្សេងៗចេញពីដីដើម្បីយកដីប្រើប្រាស់បង្កបង្កើនផល ។ នៅឆ្នាំ ១៩៨៨ ខ្លួនបានស្នើសុំទៅអាជ្ញាធរដើម្បីធ្វើប្លង់ ប៉ុន្តែអាជ្ញាធរពុំធ្វើឱ្យទេ ដោយហេតុថា ដីនេះនៅជាប់ផ្លូវជាតិលេខ ១ ហើយរដ្ឋត្រូវការពង្រីកផ្លូវជាតិនេះ ។ កន្លងមកខ្លួនធ្លាប់បានខ្ចីដីវត្តពិតមែន តែមិនមែនខ្ចីដីទំនាស់នេះទេ ហើយដីនោះខ្លួនបានប្រគល់ឱ្យវត្តវិញតាំងពីយូរយារណាស់មកហើយ ។ ចំពោះដីកំពុងមានទំនាស់នេះ ខ្លួនពុំដែលបានខ្ចីពីលោកតា ឡុង ថាវ នោះឡើយ ។/

- សាក្សីដើមចោទឈ្មោះ [redacted] **សុខុម** ថា ខ្លួនបានមកធ្វើគ្រូបង្រៀននៅសាលាព្រះជីវីធំនៅឆ្នាំ ១៩៩៥ ខ្លួនដឹងថាដីសាលារៀននេះមានព្រំប្រទល់ ខាងលិច

ទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ។

- សាក្សីដើមចោទឈ្មោះ [redacted] សាមួង ថា ខ្លួនមកបង្រៀននៅសាលាព្រះជីវីធំនៅឆ្នាំ ១៩៩៩ ខ្លួនដឹងថា ដីនៅខាងជើងសាលារៀន ជាដីសាលា ខ្លួនដឹងតាមរយៈនាយកសាលាប្រាប់ (បង្ហាញប្លង់មុនពេលមានទំនាស់) ។

- សាក្សីដើមចោទឈ្មោះ [redacted] ឈឿ ថា នៅឆ្នាំ ១៩៩៥-១៩៩៦ ខ្លួនបានឃើញទីកន្លែងទំនាស់បច្ចុប្បន្ននេះ កាលនោះមានសុទ្ធតែព្រៃ ។

- សាក្សីដើមចោទឈ្មោះ [redacted] សារឹម ថា ដីទំនាស់មានព្រំប្រទល់ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ឈ្មោះ [redacted] សាំង បោះបង្គោលប្រហែលឆ្នាំ ២០០៧ ខ្លួនពិតជាបានឃើញឈ្មោះ [redacted] សាំង ធ្វើស្រែនៅលើដីនោះពិតមែន តែតាមខ្លួនសួរគាត់ៗថា សុំពីលោកតា [redacted] ចាវ ។ ដីដែលឈ្មោះ [redacted] សាំង ធ្វើស្រែ ខ្លួនពិតជាបានដឹងថា [redacted] សាំង ខ្ចីពីលោកតា [redacted] ចាវ (ខ្ចីហើយឱ្យវិញ) ។

- សាក្សីដើមចោទឈ្មោះ [redacted] យ៉ាន ខ្លួនបានមកធ្វើគ្រូបង្រៀននៅសាលាព្រះជីវីធំនៅឆ្នាំ ១៩៩២ ខ្លួនដឹងថាដីសាលាមានព្រំប្រទល់ ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់ដីវត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ ឡុង សំណាង ។

- សាក្សីដើមចោទឈ្មោះ [redacted] ភារម្យ ខ្លួនមកបង្រៀននៅសាលាព្រះជីវីធំនៅឆ្នាំ ១៩៩៣ ខ្លួនដឹងបានថាដីទំនាស់នេះមានព្រំប្រទល់ ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ។

- សាក្សីដើមចោទឈ្មោះ [redacted] យ៉ន់ ខ្លួនដឹងថា ដីទំនាស់នោះមានព្រំប្រទល់ខាងលិចទល់ផ្លូវជាតិលេខ ១ ខាងកើតទល់វត្តព្រះជីវីធំ ខាងជើងទល់ដើមត្នោត និងខាងត្បូងទល់ដីឈ្មោះ [redacted] សំណាង ។

- សាក្សីចុងចំលើយឈ្មោះ [redacted] រ័ត្ន ថា ខ្លួនបានឃើញឈ្មោះ [redacted] សាំង គាត់ធ្វើលើដីទំនាស់នេះតាំងពីឆ្នាំ ១៩៧៩ រហូតមក ខ្លួនបានឃើញឈ្មោះ [redacted] សាំង កាប់ឆ្ការដីនេះ និងរើសសំណល់គ្រាប់ផ្ទុះដែលបន្សល់ទុកពីសម័យសង្គ្រាម ដើម្បីយកដីបង្កបង្កើនផល ហើយឃើញឈ្មោះ [redacted] សាំង ធ្វើស្រែរហូតដល់សព្វថ្ងៃ ខ្លួនធ្វើគ្រូបង្រៀននៅសាលាព្រះជីវីនៅឆ្នាំ ១៩៨៥-១៩៨៩ ក្នុងពេលដែលខ្លួនធ្វើគ្រូបង្រៀននៅសាលានេះ គឺខ្លួនបានដឹកនាំសិស្សសាលាធ្វើស្រែនៅក្បែរដីដែលមានឈ្មោះ [redacted] សាំង បង្កបង្កើនផល

ដើម្បីយកផលស្រូវមកប្រើប្រាស់ជាប្រយោជន៍សាលារៀន ឯឈ្មោះ [redacted] សាំង មិនបាន ធ្វើស្រែប្រវាស់ជាមួយសាលាទេ ។

- សាក្សីចុងចំលើយឈ្មោះ [redacted] **សារី** ថា ដីទំនាស់នេះខ្លួនបានឃើញ ឈ្មោះ [redacted] សាំង កាន់កាប់បង្កបង្កើនផលតាំងពីឆ្នាំ ១៩៧៩ មក ។ ដីទំនាស់នេះឈ្មោះ [redacted] សាំង បានមកសុំធ្វើប្លង់ ពេលនោះអាជ្ញាធរមិនអនុញ្ញាតទេ ព្រោះរដ្ឋកំពុងធ្វើការ ពង្រីកផ្លូវជាតិលេខ ១ បានជាខ្លួនដឹងរឿងនេះ ព្រោះពេលនោះខ្លួនធ្វើជាអនុប្រធានភូមិ ។

- សាក្សីចុងចំលើយឈ្មោះ [redacted] **លន់** ថា ខ្លួនបានឃើញឈ្មោះ [redacted] សាំង ចាប់បង្កបង្កើនផលលើដីទំនាស់តាំងពីក្រោយថ្ងៃរំដោះ ។

- សាក្សីចុងចំលើយឈ្មោ[redacted] **ឱុង** ថា ខ្លួនបានឃើញឈ្មោះ [redacted] សាំង ធ្វើស្រែលើដីទំនាស់តាំងពីឆ្នាំ ០៩៨០ រហូតដល់សព្វថ្ងៃនេះ ។

- សាក្សីចុងចំលើយឈ្មោះ [redacted] **សារិន** ថា នៅក្នុងឆ្នាំ ១៩៨៨ ខ្លួនជា នាយករងសាលាព្រះជីវិធំ ហើយនៅក្នុងពេលនោះខ្លួនបានឃើញឈ្មោះ [redacted] សាំង នេះ ធ្វើស្រែបង្កបង្កើនលើដីនេះរួចទៅហើយ ។

- សាក្សីចុងចំលើយឈ្មោះ [redacted] **បន** ខ្លួនដឹងថាដីទំនាស់នេះឈ្មោះ [redacted] សាំង កាន់កាប់បង្កបង្កើនផលលើដីនេះ ខ្លួនដឹងព្រោះថាខ្លួនបមានដីស្រែនៅជាប់ជាមួយដី [redacted] សាំង នេះដែរ ។ ហើយឈ្មោះ [redacted] សាំង នេះធ្លាប់បានធ្វើស្រែលើដីខ្លួន រហូតមានការប្តឹង ផ្តល់គ្នារហូតដល់តុលាការកំពូលទៀតផង ។

- តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.រ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ របស់សាលាបឋមសិក្សាព្រះជីវិធំបង្ហាញថា សាលាបឋម សិក្សាព្រះជីវិធំមានផ្ទៃដី ០៤ ហិកតា ៤២ អា ០៦ សង្ទីអា មានព្រំប្រទល់ខាងជើងទល់ ដីបំរុង ខាងត្បូងទល់ដី [redacted] សំណាង ខាងកើតទល់វត្តព្រះជីវិធំ និងខាងលិចទល់ ផ្លូវជាតិលេខ ១ ស្ថិតនៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

- តាមកំណត់ហេតុអង្កេតដីរបស់សាលាបឋមសិក្សាព្រះជីវិធំ ចុះថ្ងៃទី ១៣-៦-១៩៩៥ បង្ហាញថា ព្រំប្រទល់ដីរបស់សាលា គឺខាងជើងទល់ដីបំរុង ខាងត្បូងទល់ដី ឈ្មោះ [redacted] សំណាង ខាងលិចទល់ផ្លូវជាតិលេខ ១ និងខាងកើតទល់ដីវត្តព្រះជីវិធំ មានទំហំ ០៤ ហិកតា ៤២ អា ០៦ សង្ទីអា ។

- តាមកំណត់ហេតុដោះស្រាយបញ្ហាព្រំប្រទល់ដីសាលារៀនព្រះជីវិធំ និង លោក [redacted] បន ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៩ បានបង្ហាញថា ភាគីតំណាងឱ្យ សាលារៀនដែលលោក [redacted] ហ៊ួន នាយកសាលាព្រះជីវិធំ និងព្រះចៅអធិការ [redacted] ឈឿន

17/3

និងភាគីម្ខាងទៀតគឺលោក [redacted] បន ឯកភាពត្រូវគោរពតាមបង្គោលព្រំប្រទល់ និងទទួលស្គាល់ដោយមេឃុំ និងអាជ្ញាធរបល់ស្រុក ។ ចំពោះដីសាលារៀនព្រំប្រទល់ខាងត្បូងឈៀងខាងលិចទល់ និងផ្លូវ លោក ប៊ី បន ព្រំប្រទល់ខាងកើតឈៀងខាងត្បូងទល់ផ្លូវជាតិលេខ ១ ។

- តាមកំណត់ហេតុស្តីពីការវាយតម្លៃដីទំនាស់នៅចំណុចសាលារៀនព្រះធីរ៉ែធំ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០ បានបង្ហាញឱ្យឃើញថា ក្រោយពីការវាស់វែងជាក់ស្តែង លទ្ធផលនៃការវាស់វែងដីនេះមិនជាន់គ្នាទេ ព្រោះសាលារៀនមានបង្គោល ហើយដីឈ្មោះ [redacted] បិន មានបង្គោល ហើយនិងដីឈ្មោះ [redacted] សាំង ពុំទាន់មានបង្គោល តែបានកាន់កាប់ស្របច្បាប់តាមមាត្រា ៤២ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ រហូតមក ដូច្នេះដីទាំងបីកន្លែងនេះមិនជាន់គ្នាទេ គឺដាច់ៗពីគ្នា ។ ចំពោះបញ្ហាដែលទំនាស់គ្នានេះបណ្តាលមកពីក្រុមចុះអង្កេតវាស់វែងឆ្នាំ ១៩៩៥ នោះដាក់ឈ្មោះអ្នកកាន់កាប់ដីជាប់ព្រំចូលក្នុងកំណត់ហេតុអង្កេតវាស់វែងមិនអស់ផ្នែកខាងលិច និងខាងកើត ។

- តាមកំណត់ហេតុចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការវាស់វែងដីសាលារៀនព្រះធីរ៉ែធំ ផ្ទៀងផ្ទាត់តាមប័ណ្ណលេខ J0022 បានបង្ហាញអំពីលទ្ធផលវាស់វែងផ្ទៀងផ្ទាត់តួរលេខតាមជ្រុងនីមួយៗ ដែលមាននៅក្នុងកំណត់ហេតុអង្កេតដីច្បាប់ដើម ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៦ ចុះហត្ថលេខាដោយឯកឧត្តម [redacted] សាយឿន ឃើញថាពិតជាត្រឹមត្រូវមិនមានការជាន់គ្នាលើដីឈ្មោះ [redacted] បន និងឈ្មោះ [redacted] សាំង ទេ ។

- តាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ៧៥០ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ របស់អយ្យការខេត្តព្រៃវែង បានតម្កល់ទុកឥតចាត់ការលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ធារី ដែលប្តឹងទៅលើឈ្មោះ [redacted] បន និងឈ្មោះ [redacted] សាំង ពីបទប៉ះពាល់កម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុសាធារណៈ ។

**បានឃើញ** របាយការណ៍ស្តីពីករណីទំនាស់រវាងសាលាបឋមសិក្សាព្រះធីរ៉ែធំ និងឈ្មោះ [redacted] បន , ឈ្មោះ [redacted] សាំង ស្ថិតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០ របស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ផ្ញើជូនខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ [redacted] សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**បានឃើញ** កំណត់ហេតុចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ ពាក់ព័ន្ធការសំរុះសំរួលរបស់ភាគីសាលាបឋមសិក្សាព្រះធីរ៉ែធំ លោក [redacted] សាំង និងលោក [redacted] បន ។

**បានឃើញ** កំណត់ហេតុអនុវត្តសាលដីកាចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥ របស់តុលាការកំពូល ។



Scanned with CamScanner

17/2

**បានឃើញ** ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ព.វ ០០០៨៥៩ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ របស់វត្តព្រះជីវីធំ ។/

## **សំអាងហេតុ**

- ឆ្លងតាមការសាក [redacted] សាម៉ីភាគី និងការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា : ការប្តឹងទាមទាររបស់ដើមចោទ គឺសំអាងទៅលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ ដែលក្នុងប័ណ្ណនេះបានបញ្ជាក់ពីព្រំប្រទល់ដីសាលាព្រះជីវីធំផ្នែកខាងលិចទល់និងផ្លូវជាតិលេខ ១ ប៉ុន្តែបញ្ហានេះត្រូវសមត្ថកិច្ចជំនាញធ្វើការបំភ្លឺថា គឺកំហុសរបស់ក្រុមចុះអង្កេតវាស់វែងឆ្នាំ ១៩៩៥ នោះដាក់ឈ្មោះអ្នកកាន់កាប់ដីជាប់ព្រំចូលក្នុងកំណត់ហេតុអង្កេតមិនអស់ផ្នែកទិសខាងលិច និងខាងកើត ។ នេះអាចបញ្ជាក់បានថា ដីសាលាបឋមសិក្សាព្រះជីវីធំពុំមានការបាត់បង់នោះទេ ។/

- តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុរបស់សាលាព្រះជីវីធំ ដែលស្នើសុំដោយលោក [redacted] សុខុម ជានាយកសាលា ព្រះជីវីធំដែលមាននៅក្នុងកំណត់ហេតុអង្កេតដីចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥ គឺស្នើសុំលើដីទំហំ ០៤ ហិកតា ៤២ អា ០៦ សង្ទីអា ហើយប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ ក៏បានបញ្ជាក់ថា ដីសាលាបឋមសិក្សាព្រះជីវីធំមានទំហំ ០៤ ហិកតា ៤២ អា ០៦ សង្ទីអា ដែរ ។/

- ដីទំនាស់ដែលឈ្មោះ [redacted] សាំង កំពុងកាន់កាប់នេះ គឺជាដីដែលឈ្មោះ [redacted] សាំង បានកាន់កាប់បង្កបង្កើនផលតាំងពីឆ្នាំ ១៩៧៩ មករហូតដល់បច្ចុប្បន្ន ហើយដីនេះក៏ពុំជាន់គ្នាជាមួយនិងដីសាលាបឋមសិក្សាព្រះជីវីធំដែរ ។/

- ហេតុនេះឃើញថា ការប្តឹងទាមទារដីរបស់ដើមចោទ គឺជាការប្តឹងទាមទារដីដែលនៅក្រៅប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧ របស់សាលាបឋមសិក្សាព្រះជីវីធំ ពុំមែនទាមទារដីទៅតាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ នោះទេ ដោយហេតុថា ដីសាលាបឋមសិក្សាព្រះជីវីធំ ដែលមានទំហំ ០៤ ហិកតា ៤២ អា ០៦ សង្ទីអា ពុំមានការបាត់បង់នោះទេ ។/

- តុលាការគប្បីសម្រេចច្រានចោលការទាមទាររបស់ដើមចោទទាំងស្រុង ។

- គប្បីឱ្យដើមចោទទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។

19/1

## សេចក្តីសម្រេចបញ្ចប់

១- ច្រានចោលការទាមទារដីទំហំ ១២៥៣ ម² ដែលស្ថិតនៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង របស់ដើមចោទឈ្មោះ [redacted] សុខុម , ឈ្មោះ [redacted] សន , ឈ្មោះ [redacted] ឡាច , ឈ្មោះ [redacted] យួម និងឈ្មោះ [redacted] សាវិន ជាគណៈកម្មការវត្តព្រះជីវីធំ និងជាគណៈកម្មការទ្រទ្រង់សាលារៀនព្រះជីវីធំ ដែលមានមេធាវីតំណាងដោយអាណត្តិ គឺលោក [redacted] ។

២- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី...23...ខែ...11...ឆ្នាំ 2011

ក្រឡាបញ្ជី

[redacted]